Food and Agriculture Organization of the United Nations

IUCN

គម្រោង «លើកកម្ពស់ចីរភាពទឹកក្រោមដីឆ្លងដែន រវាងអាងទន្លេមេគង្គកម្ពុជា និងតំបន់ដីសណ្តរទន្លេមេគង្គវៀតណាម (CMDA)»

© IUCN Viet Nam

សង្ខេបគម្រោង៖

គម្រោង "លើកកម្ពស់ចីរភាពទឹកក្រោមដីឆ្លងដែនរវាង អាងទន្លេមេគង្គកម្ពុជា និងតំបន់ដីសណ្តរទន្លេមេគង្គវៀតណាម (CMDA)" គឺជាគម្រោងគ្រប់គ្រងទឹកក្រោមដីឆ្លងដែនជំជាងគេនៅតំបន់អាស៊ីភាគអគ្នេយ៍ ដែលគាំទ្រដោយមូលនិធិបរិស្ថានពិភពលោក (GEF)។ វាគឺជាគម្រោងពេញលេញមួយដែលនឹងអនុវត្តរយៈពេល៥ឆ្នាំ ដើម្បីជានាការគ្រប់គ្រងអាងទឹកក្រោមដីឆ្លងដែនប្រកបដោយនិរន្តរភាព រវាងប្រទេសកម្ពុជា និងវៀតណាម។ គំនិតផ្តួចផ្តើមនៃគម្រោងដ៏សំខាន់នេះ គឺជាការអនុវត្តនៅដំណាក់កាលទី១ នៃដំណាក់កាលទាំងបីរបស់គម្រោង ដែលគម្រោងនេះនឹងមានសក្តានុពលក្នុងការទទួលបានការគាំទ្រថវិកាពីមូលនិធិបរិស្ថានសកលបន្ថែមទៀត ដើម្បីបន្តអនុវត្តនៅដំណាក់កាលបន្តបន្ទាប់ និងបន្តអនុវត្តដំណោះស្រាយនានាដែលបានរៀបរៀងឡើងដោយគម្រោង តាមរយៈយន្តការកិច្ចសហប្រតិបត្តិការឆ្លងដែនដ៏មានសារៈសំខាន់នេះ។

គោលបំណងគម្រោង៖

ដើម្បីលើកកម្ពស់ចីរភាពបរិស្ថាន និងសន្តិសុខទឹក នៅអាងទន្លេមេគង្គក្រោមលើកដំបូង ដោយផ្តោតលើការពង្រឹងអភិបាលកិច្ច និងការប្រើប្រាស់ប្រកបដោយចីរភាពនៃតំបន់អាងទឹកក្រោមដីឆ្លងដែនរវាងអាងទន្លេមេគង្គកម្ពុជា និងតំបន់ដីសណ្តរទន្លេមេគង្គវៀតណាម។



Source: ICEM, 2021

ព្រំប្រទល់ និងឈ្មោះដែលបានបង្ហាញ និងការកំណត់សម្គាល់ដែលបានប្រើលើផែនទីនេះ/ផែនទីទាំងនេះ មិនមានន័យថាជាការបង្ហាញនូវយោបល់ណាមួយពីភាគីអង្គការ FAO ទាក់ទងនឹងស្ថានភាពច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ពាក់ព្រ័ន្ធ ព្រមទាំងការកំណត់ព្រំដែននានា។ ខ្សែបន្ទាត់ពណ៌ប្រផេះនៅលើផែនទីបង្ហាញពីព្រំដែនប្រហែលដែលអាចមិនទាន់មានការឯកភាពពេញលេញនៅឡើយ។

លទ្ធផលចម្បងរំពឹងទុក

លទ្ធផលទី១: រៀបចំរចនាសម្ព័ន្ធការណ៍ការវិភាគវិនិច្ឆ័យឆ្លងដែន និងឯកភាពរួមគ្នារវាងប្រទេសទាំងពីរ ទាក់ទងនឹងបញ្ហាប្រឈមសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលលើអាងទឹកក្រោមដី តាមរយៈកិច្ចសហប្រតិបត្តិការវិភាគវិនិច្ឆ័យស្វែងរកព័ត៌មាន និងដំណោះស្រាយរួមគ្នា។

លទ្ធផលទី២: សាកល្បងនិងអនុវត្តយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ផលិតភាពនៃការបំពេញទឹកក្រោមដី កាត់បន្ថយការជីកបូមយកទឹកក្រោមដី និងបង្ការគ្រោះថ្នាក់លើប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់នោះ។ អាទិភាពនឹងផ្តល់ឱ្យមានការចូលរួមយ៉ាងទូលំទូលាយប្រកបដោយបរិយាបន្ន និងឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងក្រុមប្រជាជនងាយរងគ្រោះ។

លទ្ធផលទី៣: ពង្រឹងអភិបាលកិច្ចឆ្លងដែន តាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសសហគមន៍តាមទីជនបទ ដាច់ស្រយាល លើដំណើរការសម្រេចចិត្តនានា។

លទ្ធផលទី៤: ធានាការកែទំរង់រយៈពេលវែង នៃលិខិតបទដ្ឋានគតិយុត្ត ស្ថាប័ន និងគោលនយោបាយ ដែលពាក់ព័ន្ធជាអាទិភាព និងការអនុវត្តមន៍ឆ្លើយតបនានា ដើម្បីការពារនិងប្រើប្រាស់អាងទឹកក្រោមដីឆ្លងដែននេះ និងប្រព័ន្ធអេកូឡូស៊ីពាក់ព័ន្ធនានាប្រកបដោយសមធម៌។

លទ្ធផលទី៥: រៀបចំយន្តការនៃប្រព័ន្ធត្រួតពិនិត្យតាមដាន ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ការសមាហរណកម្មយែនឌ័រ ដើម្បីជានាចីរភាពរយៈពេលវែងនៃលទ្ធផលឬតទ្ធិពលរបស់គម្រោង។

រយៈពេលអនុវត្តគម្រោង៖ ខែមីនា ឆ្នាំ២០២៤ ដល់ ខែធ្នូ ឆ្នាំ២០២៨

ដៃគូដោ្ឋកិបាលអនុវត្តគម្រោង៖ អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន ប្រទេសកម្ពុជា និងនាយកដ្ឋានគ្រប់គ្រងធនធានទឹក នៃក្រសួងកសិកម្ម និងបរិស្ថាន ប្រទេសវៀតណាម។

ភ្នាក់ងារដឹកនាំសម្របសម្រួលនិងអនុវត្តគម្រោង៖ អង្គការ FAO និងអង្គការ IUCN

ដៃគូភ្នាក់ងារអនុវត្តគម្រោង៖ អង្គការ UNESCO, វិទ្យាស្ថាន MERFI, វិទ្យាស្ថាន និងសាកលវិទ្យាល័យជាតិនានា។

ទីតាំងអនុវត្តគម្រោង៖ ប្រទេសកម្ពុជា និងប្រទេសវៀតណាម។

ព័ត៌មានទំនាក់ទំនង៖

ប្រធានក្រុមប្រឹក្សាបច្ចេកទេស - លោកស្រី ណាណាបារ៉ាមីដ(ណានីកូ) | អ៊ីម៉ែល: nana.baramidze@iucn.org

ការិយាល័យរបស់អង្គការ IUCN នៅប្រទេសកម្ពុជា

ជាន់ទី៥ បន្ទប់លេខ៥៨៩ ប្លុក "អគារខាងត្បូងH" មជ្ឈមណ្ឌលភ្នំពេញ វិថីសុផារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

គេហទំព័រ៖ https://iwlearn.net/ | ទំព័រ ហ្វេសប៊ុក: Cambodia - Mekong River Delta aquifer CMDA Project

© IUCN Cambodia

unesco

MEKONG REGION FUTURES INSTITUTE

gef

Some rights reserved. This work is available under a CC BY-NC-SA 3.0 IGO licence

© FAO, 2025
CD4321EN/1/02.25